# ទីបន្ទាល់ម្ដាយមួយរូបក្នុងគុក ~ ហេង គឹមនាង




មូលហេតុដែលបណ្ដាលឱ្យនាងខ្ញុំទៅជាប់ក្នុងពន្ធនាគារអស់រយៈពេល៤០ថ្ងៃមិនមែនជាការដែលនាងខ្ញុំបានប្រព្រឹត្តទេ គឺដោយសារការបៀតបៀនពីព្រោះគេស្អប់ខ្ញុំជាអ្នកជឿព្រះយេស៊ូ ។

គេបានមកនោមដាក់អាងទឹកខ្ញុំ ហើយកប់ដុំថ្មចោលក្នុងផ្ទះខ្ញុំ ហើយថែមទាំងយកដំបងមកវាយខ្ញុំទៀត ស្រាប់តែពេលនោះកូនមកទាន់ក៏បានជួយឃាត់ ហើយចាប់ដំបងចេញ ។ កូនប្រុសខ្ញុំឃើញគាត់ជាមនុស្សស្រវឹងហើយក៏បានបែកគ្នាទៅផ្ទះរៀងៗខ្លួនទៅ ក្រោយមកតានោះក៏បានជិះម៉ូតូទៅប្ដឹងប៉ូលីសព្រហ្មទន្ឌ ។

ស្នែកឡើងប៉ូលីសក៏បានហៅរូបខ្ញុំឡើងទៅ ដោយបង្ខំនាងខ្ញុំឱ្យបង់លុយដោយមិនបានឃើញស្លាកស្នាមអ្វីជាភស្តុតាងឡើយ ពេលនោះនាងខ្ញុំមិនព្រមបង់ពីព្រោះនាងខ្ញុំមិនបានប្រព្រឹត្តការនោះឡើយ គេមិនបានដោះស្រាយទៀតទេ គេក៏បានបញ្ជូននាងខ្ញុំទៅដោះស្រាយនៅតុលាការខេត្តកោះកុងប៉ុន្តែតុលាការមិនបានដោះស្រាយអ្វីឡើយ ។

គេក៏បានបញ្ជូននាងខ្ញុំព្រមទាំងកូចូលមកក្នុងពន្ធនាគារតែម្ដង ។ ពេលនោះនាងខ្ញុំអស់សង្ឃឹមជាខ្លាំង គ្មានអ្វីជាទីពឹងឡើយពេលនោះនាងខ្ញុំក៏បានអធិស្ឋានដោយអស់ពីចិត្ត ។

ខ្ញុំមានការភ័យតក់ស្លុតជាខ្លាំងក្រោយពីឃើញឡានទ្រុងដែលគួរឱ្យខ្លាចនោះ ។ គេមិនបានដាក់នាងខ្ញុំឱ្យជិះក្នុងឡានទ្រុងនោះឡើយ តែគេឱ្យនាងខ្ញុំជិះឡានរបស់ព្រះរាជអាជ្ញាប្រធានតុលាការវិញ ។ នេះជាការអស្ចារ្យលើកទី១ ដែលព្រះអង្គបានជួយរូបនាងខ្ញុំនៅពេលដែលខ្ញុំអធិស្ឋានទៅទ្រង់នៅពេលដែលមានអាសន្ន ។

ពេលមកដល់ឃើញ ផ្លាកពន្ធនាគារនាងខ្ញុំភ័យខ្លាចខ្លាំងណាស់ គ្មានអ្វីសង្ឃឹមក្រៅពីការអធិស្ឋានឡើយ ពេលដែលគេបើកទ្វារនាំនាងខ្ញុំចូលទៅ ស្រាប់តែមានមនុស្សម្នាក់កាន់ដំបងដើរសំដៅមករកនាងខ្ញុំ

នាងខ្ញុំខ្លាចណាស់ នាងខ្ញុំក៏និយាយក្នុងចិត្តថា បិតាអើយ ជួយកូនផង ។ ពេលគេដើរមកជិតដល់នាងខ្ញុំ គេគ្រាន់តែមើលមុខនាងខ្ញុំ ហើយក៏ដាក់ដំបងចុះព្រមទាំងដើរចេញទៅផងដែរ ។

គេក៏នាំនាងខ្ញុំដើរទៅមុខទៀត ស្រាប់តែឃើញមនុស្សមាឌធំខ្មៅ កាន់ដំបងដើរសំដៅមករកនាងខ្ញុំទៀត ។ ពេលនោះនាងខ្ញុំគិតម្តងទៀតថា ម្តងនេះនាងខ្ញុំប្រហែលជាមិនរួចខ្លួនទេ តែនាងខ្ញុំនៅតែស្រែករកព្រះឱ្យជួយ ។ ពេលដែលគេដើរមកដល់គេមិនបានវាយកូនខ្ញុំទេ គេគ្រាន់តែស្រែកសំលុតឱ្យដោះខោអាវចេញ ។ គេទាំង២នាក់នោះជាប្រធានខាងវិន័យសណ្តាប់ធ្នាប់ ពេលគេនាំទៅកាន់បន្ទប់ដែលយើងនឹងចូលទៅពេលដែលចូលទៅហើយអ្នកទោសចាស់គេតែងតែវាយអ្នកទោសដែលចូលថ្មីជាការស្វាគមន៍ មិនដែលលើកលែងមួយណាឡើយ ស្រាប់តែពេលនោះមានម្នាក់ជាអ្នកទោសដែរ ក៏បានស្រែកប្រាប់ថាមិនឱ្យវាយគាត់ទេ បើសិនជាឯងហ៊ានវាយគាត់អញនឹងឱ្យគាត់វាយឯងវិញ ។

ទាំងអស់នេះសុទ្ធតែជាការអស្ចារ្យរបស់ព្រះជាម្ចាស់ ដែលបានជួយការពារនៅពេលដែលមានអាសន្នដូចជាព្រះបន្ទូលដែលទ្រង់បានសន្យាមែនហើយប្រធានទាំង២នាក់ដែលសុទ្ធជាមនុស្សកាចសាហាវគ្មានអ្នកណាហ៊ានមើលមុខចំឡើយ ស្រាប់តែមកសុំកូនប្រុសខ្ញុំធ្វើជាមិត្តភ័ក្ត ហើយក៏និយាយថាអញឃើញមុខឯងអញលើកដៃវ៉ៃមិនរួចទេអញឃើញម្តាយឯងដូចជាម្តាយអញ ។ ពេលនោះគេក៏បានមកសុំនាងខ្ញុំធ្វើជាម្តាយ ខ្ញុំក៏ចាប់ផ្តើមមានសង្ឃឹមពីព្រោះមានកូនធម៌ជាប្រធានគុក ហើយវាបានប្រាប់ខ្ញុំថា បើវាមិនវ៉ៃគ្មានអ្នកណាវ៉ៃទេ ។

នាងខ្ញុំក៏ចាប់ផ្តើមផ្សាយដំនឹងល្អតាមរយៈការនិទានរឿង ព្រះបង្កើតផ្ទៃមេឃ និងផែនដី អាដាំ អេវ៉ា ហើយណូអេ និងរឿងអាប្រាហាំ ឱ្យពួកអ្នកទោសទាំងអស់នោះបានស្តាប់ ប៉ុន្តែពួកគេគ្រាន់តែស្តាប់មិនទាន់យល់ ។

ពេលនោះនាងខ្ញុំនឹងឃើញពេលដែលចូលមកដល់ គេហៅនាងខ្ញុំថាចោរថ្មីពេលនោះនាងខ្ញុំក៏បាននិទានរឿង ចោរ២នាក់ជាប់ឆ្កាងជាមួយនឹងព្រះ រួចនាងខ្ញុំសួរគេថា តើចោរទាំង២នាក់នោះត្រូវយកមួយណា គេក៏បានរើសយកចោរទី២ ពេលនោះនាងខ្ញុំមានឱកាសក៏បាននាំគេថ្វាយបង្គំអធិស្ឋានចំនួន៦នាក់ជាសេចក្តីជំនឿដ៏ពិតតាមរយៈនិទាន រឿង ហើយមានស្រីម្នាក់ឈ្មោះ វី គេក៏បានថ្វាយខ្លួនផងដែរ ព្រះអង្គបានធ្វើការអស្ចារ្យ ដោយប្រទានម្ហូបអាហារនៅទីនោះឱ្យបានបរិបូរណ៍ ហើយបានចាត់អ្នកជំនួយដូចជាពេទ្យព្រមទាំងមានអ្នកលើកទឹកចិត្តផងដែរ ។

ក្រោយពីពេលដែលមានរឿងនេះកើតឡើងមក នាងខ្ញុំមានទុក្ខលំបាកដោយបាត់បង់ទ្រព្យសម្បត្តិ ដូចជាម៉ូតូនិងផ្ទះ តែនាងខ្ញុំមិនសោកស្តាយទេ ។

តែនាងខ្ញុំបានមកវិញនូវសេចក្តីជំនឿដ៏រឹងមាំ ដែលព្រះអង្គបានធ្វើការអស្ចារ្យមកលើគ្រួសារនាងខ្ញុំឱ្យមានការផ្លាស់ប្រែជាមនុស្សថ្មី ។ នាងខ្ញុំសូមអរគុណដល់ព្រះអង្គដោយសេចក្តីអំណរ ។ នាងខ្ញុំជាម្តាយឈ្មោះ *ហេងគីមនាង* កូនប្រុសឈ្មោះ *ហេងគីមសៀង* និងកូនស្រីឈ្មោះ *ហេងស្រីមុំ* ។

**អរគុណព្រះអង្គយេស៊ូ អាម៉ែន !**

---